អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មានរបស់អង្គភាពគាំពារការការពារក្តី

អង្គភាពគាំពារការការពារក្តី (“អ.គ.ក”) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានចាត់តាំងលោកស្រី ដូរីន ឆិន (Doreen Chen) ជនជាតិអូស្ត្រាលី ឲ្យធ្វើជាសហមេធាវីបរទេសថ្មីតំណាងលោក នួន ជា ក្នុងសំណុំរឿង ០០២/០២។

លោកស្រី ដូរីន ឆិន ជាមេធាវីជំនាញផ្នែកសិទ្ធិមនុស្ស ដែលបានបម្រើការងារជាទីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់លោក នួន ជា នៅ អ.វ.ត.ក ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ ។ ការប្រកបវិជ្ជាជីវៈផ្នែកច្បាប់ជាក់ស្តែងដ៏ទូលំទូលាយរបស់គាត់ គឺផ្តោតលើការធ្វើជាតំណាងឲ្យអ្នកការពារសិទ្ធិមនុស្សដែលរងការធ្វើទុក្ខបុកម្នេញ និងសហគមន៍ដែលងាយរងគ្រោះនៅទ្វីបអាស៊ី រួមទាំងនៅចំពោះមុខផ្នែកយន្តការសិទ្ធិមនុស្សរបស់ អ.ស.ប និងបំពេញមុខងារជារដ្ឋអាជ្ញានាំមុខ (Lead Prosecutor) នៅតុលាការប្រជាជនអចិន្ត្រៃយ៍ស្តីពីប្រទេសភូមា។ លោកស្រីក៏ជាសហស្ថាបនិក និងសហនាយកដឹកនាំអង្គការក្រៅរដ្ឋាភិបាលស្តីពីគោលដៅយុត្តិធម៌ ដែលបម្រើកិច្ចការផ្នែកនីតិរដ្ឋ សិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបានព័ត៌មាននៅក្នុងប្រទេសកម្ពុជា ព្រមទាំងកិច្ចការផ្សេងៗទៀត និងជាមន្ត្រីសម្របសម្រួលផ្នែកច្បាប់អន្តរជាតិជាមួយសម្ព័ន្ធសេរីជនជាតិរ៉ូហ៊ីងយ៉ា។ ក្នុងចំណោមភារកិច្ចជាច្រើនទៀត លោកស្រី ដូរីន ឆិន ក៏ធ្លាប់បំពេញកិច្ចការផ្នែកពិគ្រោះយោបល់ឲ្យការិយាល័យសិទ្ធិមនុស្ស អ.ស.ប រួមទាំងបានជួយរៀបចំ*សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា*លើកទីមួយ។ គាត់ក៏ធ្លាប់បានបង្រៀនច្បាប់អន្តរជាតិ សិទ្ធិមនុស្ស និងវិទ្យាសាស្ត្រនយោបាយ នៅតាមសាកលវិទ្យាល័យនានានៅប្រទេសកម្ពុជា ប្រទេសបារាំង និងប្រទេសអូស្ត្រាលីផងដែរ។ លោកស្រីទទួលបានសញ្ញាប័ត្រ LL.M ពីសាកលវិទ្យាល័យកូឡុំប៊ី នៅក្នុងទីក្រុងញូវយ៉ក និងបានទទួលការអនុញ្ញាតឲ្យបំពេញការងារនៅតុលាការកំពូលនៃរដ្ឋ New South Wales ក្នុងប្រទេសអូស្ត្រាលី។

លោកស្រី ដូរីន ឆិន នឹងបំពេញភារកិច្ចរួមគ្នាជាមួយសហមេធាវីជាតិលោក សុន អរុណ ដើម្បីធ្វើជាតំណាងលោក នួន ជា នៅចំពោះមុខ អ.វ.ត.ក។ ចំពោះការចាត់តាំងនេះ អ.គ.ក បានពិចារណាដល់ការយល់ព្រមទទួលយកពីសំណាក់លោក នួន ជា និងការលះបង់សិទ្ធិលើទំនាស់ផលប្រយោជន៍ដែលអាចយកមកអនុវត្តបាន។